**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារ

កិច្ចព្រមព្រៀងព្យួរកិច្ចសន្យាការងារនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២១ រវាង លោក **ហែម សក្ដណា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៩៣៧៤០៥ ដែលមានតួនាទី **នាយកគ្រប់គ្រងទូទៅ** និងជាតំណាងភាគីនិយោជក នៃក្រុមហ៊ុន **អិល&អិម បាសាក់រីវើរ ខូ អិលធីឌី** ដែលមានអាសយដ្ឋានស្ថិតនៅ **អាគារលេខ អិន២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ** ធ្វើជាមួយនិង ៖

- លោកស្រី **ទុន ស្រីត័ក្ត** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១០៦៨៥០៤៤ ដែលមានតួនាទីជាជំនួយការប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។
- លោកស្រី **អ៊ុំ សៅឌីណា** កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ ០១១៣៦០៤៤៤ ដែលមានតួនាទីជាជំនួយការប្រធានផ្នែកគ្រប់គ្រងភោជនីយដ្ឋាន និងជាតំណាងភាគីនិយោជិកនៃក្រុមហ៊ុនខាងលើ។

ភាគីទាំងពីរបានធ្វើការព្រមព្រៀងគ្នាដូចខាងក្រោម៖

១-រយៈពេលនៃការព្យួរកិច្ចសន្យាការងារ ៖

ការព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ចំនួនកម្មករសរុប ២៧០នាក់ ស្រី ១២៩នាក់ កម្មករព្យួរកិច្ចសន្យាការងារមាន ៨៧នាក់ ស្រី ៤១នាក់ មូលហេតុដោយសារក្រុមហ៊ុនបានទទួលរងនូវផលប៉ះពាល់យ៉ាងអវិជ្ជមានលើផ្នែកហិរញ្ញវត្ថុ ដែលបង្កដោយវីរុស កូវីដ-១៩ ។

២-ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ៖

ភាគីនិយោជក មិនមានផ្ដល់ជាប្រាក់ឧបត្ថម្ភអ្វីឡើយ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ។

ភាគីនិយោជិត មិនទាមទារប្រាក់ឧបត្ថម្ភអ្វីឡើយ ពីនិយោជក ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ។

៣-កាលបរិច្ឆេទចូលបម្រើការងារវិញ ៖

បុគ្គលិកនិយោជិកទាំងអស់ត្រូវត្រឡប់ចូលមកបម្រើការងារវិញ បន្ទាប់ពីរយៈពេលព្យួរកិច្ចសន្យាការងារនេះត្រូវបានបញ្ចប់។ កិច្ចសន្យានេះត្រូវបានធ្វើឡើងជាពីរ(០២)ច្បាប់ និងមានតម្លៃស្មើគ្នាចំពោះមុខច្បាប់ ដែលសម្រាប់ភាគីនីមួយៗទុកម្នាក់មួយ(០១)ច្បាប់។ ភាគីទាំងពីរបានអាន ព្រមព្រៀងគ្នា និងបានផ្ដិតមេដៃ ដើម្បីជាសាក្ខីភាព។

រាជធានីភ្នំពេញថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២១

| **តំណាងប្រតិភូពេញសិទ្ធ** | | **តំណាងភាគីនិយោជិត** |
|---|---|---|
| **លោកស្រី ទុន ស្រីត័ក្ត** | **លោកស្រី អ៊ុំ សៅឌីណា** | **លោក ហែម សក្ដណា** |